# ច្បាប់ បណ្តោះអាសន្ន ?

របប ក្រុងភ្នំពេញ ហៅថា របប ៣១ កុម្ភៈ ធ្វើ ច្បាប់ បណ្តោះអាសន្ន សំរាប់ គ្រប់គ្រង នគរ នៅក្នុង ភាពអាសន្ន ដែល អាចយកមក អនុវត្តបាន គ្មានកំណត់ ថ្ងៃផ្តើម ថ្ងៃបញ្ចប់ ព្រោះ ទុកលទ្ធភាព អោយ រដ្ឋាភិបាល ជា អ្នកបកស្រាយ តែ ម្នាក់ឯង លើស្ថានភាព ដែល ទុក ជា ភាពអាសន្ន នៅពេល ដែល យក ច្បាប់នោះ ទៅ អនុវត្ត ដែល ធ្វើឡើង សំរាប់ បរិបទមួយ ច្បាស់លាស់គឺ ទប់ស្កាត់ ជម្ងឺ កូវីដ ១៩។ លក្ខខណ្ឌ បែបនេះ វា ជា ច្បាប់អធម្មនុញ្ញ ព្រោះ ភាពអាសន្ន នៃ ជម្ងឺ កូវីដ ១៩ វា មិនអាចយកធ្វើ ជា ឱសភាការណ៍ (généralité) បាននោះឡើយ ដ្បិត ភាពអាសន្ន នីមួយៗ វា មាន អាការ របស់វា ខុសៗគ្នា។ ដូច្នេះ ភាពអាសន្ន នីមួយៗ ត្រូវតែធ្វើ ការពិនិត្យ ឬ ដេញប្រយោគ ជា ថ្មីសំរាប់ ធានា នូវ ធម្មនុញ្ញភាព នៃ ច្បាប់។ ការប្រកាស ថ្មីៗនេះរបស់ មេដឹកនាំ របប ថ្ងៃទី ៣១ កុម្ភៈ ថា ស្រុកខ្មែរ វា មិនទាន់មាន ភាពអាសន្ន នោះទេ វា ជា មោឃកម្ម ដោយស្វ័យប្រវត្តិ នៃគម្រោង ច្បាប់ ដាក់ ប្រទេស នៅក្នុង ភាពអាសន្ន រួចទៅហើយដូច្នេះ រដ្ឋសភា មិនអាច យក សំណើ នៃ ច្បាប់ របស់ រដ្ឋាភិបាល ទៅ ពិនិត្យ បាននោះឡើយ ព្រោះ វា គ្មាន ហេតុ។ មេដឹកនាំនោះ និយាយ បន្ថែម ថា « អ្វីៗ ក៏អញ ដឹកដែរ » ដូច្នេះ គេ អាចសួរគាត់ ថា « បើឯងដឹង ចុះហេតុអ្វី ក៏ឯងធ្វើ ?»។ ដឹកនាំ បែប« ល្ងង់ និង កំណាច » វា ជា វិនាដកម្ម ឬ អាសន្នរោគ សំរាប់ប្រជាជាតិ។